**បន្ថែមលើការទទួលទានទឹកស្អាត សូមអនុវត្តអនាម័យដូចខាងក្រោមនេះ ដើម្បីអោយគ្រួសារអ្នក មានសុខភាពល្អ**

លាងដៃជាមួយសាប៊ូអោយបានញឹកញាប់



លាងបន្លែផ្លែឈើអោយបានស្អាត



គ្របចំណីអាហារអោយបានត្រឹមត្រូវ



លាងសំអាតធុង ពាងដាក់ទឹកអោយស្អាត



គ្របពាងអោយបានត្រឹមត្រូវ



IDE international development enterprises

ធនាគារពិភពលោក




**អាសយដ្ឋានទំនាក់ទំនង** (Communication)

សាខាកាកបាទក្រហមកម្ពុជា, ខេត្តព្រៃវែង
**(CRC/Prey Veng Branch)**
Fax/Phone: 043 944 538
H/P: 011 742 719, 012 250 651
012 772 219 / 011 545 368
E-mail : crcpvgcwf@yahoo.com
song_maocrcpvg@yahoo.com

ទីស្នាក់ការកាកបាទក្រហមកម្ពុជា, ភ្នំពេញ
**(CRC/P.P)**
- នាយកដ្ឋានកម្មវិធី : 012 688 081
- ការិយាល័យទឹកស្អាត / អនាម័យ : (wat / san): 012 976 805

កាកបាតក្រហមអាមេរិកកាំង, ភ្នំពេញ
**(American Red Cross/P.P)**
Tel: 023 211 996, 023 211 542
Fax: 023 214 105

**អ្នកទើបតែទទួលបានចំរោះទឹកស្អាតរូបទន្សាយរបស់កាកបាទក្រហមកម្ពុជា ។**
**សូមធ្វើតាមការណែនាំខាងក្រោមនេះដើម្បីទទួលបាន :**

- ទឹកថ្លា ទឹកគ្មានមេរោគ និង ទឹកមានរសជាតិល្អ
- សុខភាពល្អក្នុងក្រុមគ្រួសារ
- កាត់បន្ថយការចំណាយផ្សេងៗ
- ចំណេញពេលវេលា



## ១. មុនប្រើផើងចំរោះលើកដំបូង

- ត្រូវត្រាំផើងចំរោះនៅក្នុងទឹកថ្លារយះពេល១២ម៉ោងសិន វិធីនេះអាចជួយបំបាត់ក្លិនដីឥដ្ឋ ។




- លាងសំអាតធុងតំរង គំរបធុងនិងក្បាលរ៉ូប៊ីណេជាមួយសាប៊ូអោយស្អាតសិន ។



## ២. ការប្រើប្រាស់ប្រចាំថ្ងៃ

- ត្រូវដាក់ចំរោះនៅកន្លែងដែលមានសុវត្ថិភាព ដើម្បីកុំអោយមនុស្សដើរទង្គិច ( អាចចងភ្ជាប់នឹងជញ្ជាំងផ្ទះ ឬក៏ចងភ្ជាប់នឹងសរសរផ្ទះក៏បាន )



- បើទឹកក្រខ្វក់ពេក ត្រូវចងក្រណាត់ត្រងនឹងមាត់ផើងដើម្បីត្រងជាតិក្រខ្វក់ និងកំទេចកំទីចេញ ។



- ត្រូវចាក់ទឹកបំពេញផើងចំរោះអោយបានញឹកញាប់ដើម្បីអោយចំរោះហូរលឿន ។



## ៣. ការលាងសំអាត

- ត្រូវឧស្សាហ៍លាងសំអាតធុងតំរង និងក្បាលរ៉ូប៊ីណេជាមួយទឹកសាប៊ូ ហើយហាលថ្ងៃអោយស្ងួតសិន ចាំដាក់ទឹកប្រើទៀត ដើម្បីកុំអោយកើតមានមេរោគ ។



- លាងសំអាតគំរបធុងជាមួយសាប៊ូ ហើយហាលថ្ងៃអោយស្ងួត ។



**ពេលដែលផើងចំរោះលែងហូរទឹក នោះមានន័យថាមានកករច្រើនកកនៅតាមរន្ធចំរោះ ដូច្នេះ ត្រូវលាងផើងចំរោះនោះចេញសិន :**

- ដុសសំអាតផើងជាមួយនឹងក្រណាត់ឬច្រាសទន់ៗ ហើយលាងសំអាតវាជាមួយនឹងទឹកថ្លា ។
- ហាមប្រើសាប៊ូក្នុងការលាងសំអាតផើង ។



- ត្រូវដាក់ផើងចូលទៅក្នុងធុងតំរងវិញភ្លាមបន្ទាប់ពីសំអាតរួចដើម្បីការពារការឆ្លងមេរោគផ្សេងៗមិនបាច់ហាលថ្ងៃ ផើងចំរោះទេ ។



- ត្រូវលាងកែវជាមួយសាប៊ូអោយបានញឹកញាប់



- ហាមប៉ះផ្ទៃខាងក្នុងឬ ខាងក្រៅនៃផើងនិងផ្ទៃខាងក្នុងនៃតំរង ឬក៏ប៉ះមាត់ក្បាលរ៉ូប៊ីណេទឹក ។

